ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

Ministry of Environment

លេខ: ១៣៥ ប្រក ប.ស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១២

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃក្តៅ" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិតែល ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃក្តៅ" ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១២
- តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## សម្រេច

**ប្រការ១** : រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃក្តៅ" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិតែល ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ។

លេខ ៤៨ វិថីព្រះសីហនុ ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១ ៣៩ ០៨ ០២៣ ២២ ០៣ ៦៩ ទូរសារ : ៨៥៥ ២៣ ២១ ២៥ ៤០

ប្រការ២ : សហគមន៍តំបន់ការពារធម្មជាតិ "ព្រៃផ្តៅ" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានទំហំផ្ទៃដីចំនួន ១៥៨២ ហិចតា ដូចមានផែនទីជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម ៖

| ចំណុច | X | Y |
|---|---|---|
| A | 442151 | 1542359 |
| B | 447993 | 1542344 |
| C | 448055 | 1539664 |
| D | 442126 | 1539665 |

ប្រការ៣ : ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ"ព្រៃផ្តៅ" នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពី តំបន់ការពារធម្មជាតិ។

ប្រការ៤ : អគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានកម្រងតំបន់ការពារធម្មជាតិ"ស្ទឹងសែន" ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ នាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និង សហគមន៍តំបន់ការពារធម្មជាតិ"ព្រៃផ្តៅ" ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មុខ ម៉ារ៉េត

បណ្ឌិត.ជីវវិទូ

<u>ចម្លងជូន:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-សាលាខេត្តព្រះវិហារ

-ដូចប្រការ៤ "ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ

ផែនទីសហគមន៍តំបន់ការ ម្មជាតិ "ព្រៃខ្មៅ" ស្ថិតក្នុងដែនជម្រកសត្វព្រៃ បន-ព្រហ្មទេព

ភូមិសាស្ត្រភូមិគោល ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ




**សញ្ញាសំគាល់**

- ចំណុចនិយាមការ
- ទីតាំងសហគមន៍តំបន់ការពារធម្មជាតិ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង. អូរ
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:50,000

0 1 2 Kilometers

Indian_1960_UTM_Zone_48N

| ID | N | X | Y |
|---|---|---|---|
| 1 | A | 442151 | 1542359 |
| 2 | B | 447993 | 1542344 |
| 3 | C | 448055 | 1539664 |
| 4 | D | 442126 | 1539665 |